ANFREL Asian Network for Free Elections　CHRAC　ខុមហ្វ្រែល COMFREL　និកហ្វិច NICFEC　People's Forum on CAMBODIA JAPAN

**គណៈកម្មាធិការប្រព្រឹត្តិកម្ម　គណៈកម្មាធិការខុមហ្វ្រែល　គណៈកម្មាធិការនិកហ្វិច**

# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# បរិយាកាសមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨

*ទីស្នាក់ការកណ្តាលខុមហ្វ្រែល ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨*

**សម្ព័ន្ធអង្គការសង្គមស៊ីវិល** វាយតម្លៃ បរិយាកាសមុនថ្ងៃបោះឆ្នោតថា ហាក់កំពុងជួបបញ្ហា**អសន្តិសុខតានតឹង ដែលកើតពីករណីគំរាមកំហែង បាញ់សម្លាប់**សកម្មជនគណបក្សនយោបាយ ពិសេសឃាតកម្មទៅលើអ្នកសារព័ត៌មានដែលគាំទ្រគណបក្សប្រឆាំង (គណបក្សសមរង្ស៊ី) រហូតដល់សភាពការណ៍នៃការដាក់ពង្រាយកងកម្លាំងយោធាថៃ និងកម្ពុជា នៅក្នុងតំបន់ប្រាសាទព្រះវិហារ និងបរិយាកាស**ខ្វះអព្យាក្រឹតភាព ដោយការចូលរួមដ៏ច្រើននៃមន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន** កងកម្លាំងទ័ព និងកងនគរបាល ដែលបានចូលរួមគាំទ្រគណបក្សកាន់អំណាច ហើយក៏បានប្រឆាំងគណបក្សផ្សេងទៀត។

លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល និងជាប្រធានសមាគមអាដហុក បានមានប្រសាសន៍ថា *"ដោយសារមានព្រឹត្តិការណ៍នៅតំបន់ប្រាសាទព្រះវិហារនោះ បានធ្វើឱ្យអ្នកបោះឆ្នោតមានការចាប់អារម្មណ៍យ៉ាងខ្លាំង ដូច្នេះការជម្រុញឱ្យអ្នកបោះឆ្នោតងាកមកយកចិត្តទុកដាក់លើព្រឹត្តិការណ៍បោះឆ្នោតនេះវិញ វាពិតជាមានសារៈសំខាន់។*

លោក **ធន សារាយ** ក៏មានការព្រួយបារម្ភពីការលំបាក **និងឧបសគ្គដល់អ្នកបោះឆ្នោតមួយចំនួនក្នុងពេលបោះឆ្នោតនៅថ្ងៃទី ២៧ ខែកក្កដា ខាងមុខនេះ ដូចជាការពិបាករកឈ្មោះ ឬលេខការិយាល័យជាដើម។**

ការសង្កេតតាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ មក ១ ឬ ២ ថ្ងៃមុនការបោះឆ្នោត (ឬគេតែងហៅថា **រាត្រីឆ្កែព្រុស**) បានរកឃើញថា **មានការឱ្យលុយ ឬ/និងសន្យាចែកសម្ភារៈដល់អ្នកបោះឆ្នោត** ដោយគណបក្សនយោបាយតែងតែកើតមានបន្ថែមលើអ្វីដែលសម្ព័ន្ធអង្គការសង្គមស៊ីវិល ព្រួយបារម្ភ ក្នុងការបោះឆ្នោតលើកនេះ **អាចមានការឱ្យលុយ និងសម្ភារៈដល់អ្នកបោះឆ្នោត** មិនត្រឹមតែទាក់ទាញអ្នកបោះឆ្នោតឱ្យទៅបោះឆ្នោតឱ្យគណបក្សរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏**អាចជាមធ្យោបាយរារាំងអ្នកបោះឆ្នោតក្នុងការទៅបោះឆ្នោតឱ្យគណបក្សផ្សេងផងដែរ។**

មានការ**កើនឡើងនូវអំពើហិង្សា** ដូចជា ករណីឃាតកម្ម ការបង្ករបួសស្នាម លើសកម្មជន អ្នកគាំទ្រគណបក្សនយោបាយ ជាពិសេសក្នុងកំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត។ គ្រាន់តែក្នុងកំឡុងពេលពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៨ មកទល់នឹងថ្ងៃបញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោតនេះ[១] មានករណីឃាតកម្មទៅលើសកម្មជន អ្នកគាំទ្រគណបក្ស

---

[១] យោងតាមរបាយការណ៍អង្កេតរបស់បណ្តាញ ខុមហ្វ្រែល-អាដហុក។

នយោបាយ អ្នកសារព័ត៌មាន សរុបចំនួន ៦ ករណី ជាពិសេសករណីឃាតកម្មទៅលើ លោក ឃឹម សម្បូណ៌ និងកូនប្រុស បានកើតឡើង ដែលបានធ្វើឱ្យមានមនុស្សស្លាប់ ចំនួន ៧ នាក់ ក្នុងនោះគណបក្សប្រជាជនកម្ពុជា រងគ្រោះចំនួន ៤ ករណី ដែលមួយករណីនៅខេត្តកំពង់ស្ពឺត្រូវបានគណបក្សសិទ្ធិមនុស្សអះអាងថា ជាសមាជិករបស់ខ្លួនដែរ ចំណែកគណបក្សសម រង្ស៊ីរងគ្រោះចំនួន២ករណី ហើយករណីភាគច្រើន ជនល្មើសមិនត្រូវបានស្វែងរកចាប់ខ្លួនមកផ្តន្ទាទោសនៅឡើយទេ ហើយ អាជ្ញាធរតែងអះអាងថា ករណីទាំងនេះ មិនជាប់ពាក់ព័ន្ធនឹងបញ្ហានយោបាយទេ។

បើគិតចាប់តាំងពីខែ កក្កដា ឆ្នាំ ២០០៧ មកដល់មុនថ្ងៃចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនេះមានករណី ឃាតកម្មចំនួន **១៥** ករណី[២] បានកើតឡើងចំពោះសមាជិក សកម្មជន អ្នកគាំទ្រគណបក្សនយោបាយក្នុងនោះ គណបក្ស សមរង្ស៊ី រងគ្រោះ ៧ករណី គណបក្សនរោត្តមរណឫទ្ធិ ៣ ករណី គណបក្សប្រជាជនកម្ពុជា ៤ ករណី គណបក្សសិទ្ធិមនុស្ស ១ ករណី។

ខេត្ត/ក្រុង ដែលមានករណីឃាតកម្មទាំងពីរដំណាក់កាលនេះមានដូចជា កំពង់ចាម ៤ ករណី បន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ សៀមរាប ២ ករណី ក្នុងខេត្តនិមួយៗ និងកំពង់ឆ្នាំង កំពត កណ្តាល ភ្នំពេញ ព្រះវិហារ រតនៈគិរី ស្វាយរៀង តាកែវ ប៉ៃលិន ១ ករណី ក្នុងខេត្តនិមួយៗ។

ក្រៅពីករណីឃាតកម្ម ការសង្កេត[៣]ក៏រកឃើញ **ករណីបង្ករបួសស្នាម គំរាមកំហែងផ្សេងទៀត** ប្រមាណ **៥៦** ករណី បានកើតមានចំពោះសមាជិក សកម្មជន អ្នកគាំទ្រគណបក្សនយោបាយនានានៅស្ទើរគ្រប់ខេត្ត/ក្រុងផងដែរ។ **មន្ត្រីរាជ-ការស៊ីវិល កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន** បានចូលរួមសកម្មភាពគាំទ្រគណបក្សប្រជាជនកម្ពុជាជាច្រើន រួម ទាំងការប្រឆាំងគណបក្សផ្សេងៗ និងការរំលោភច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោត ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ គណបក្សនយោបាយ ដូចជាការទម្លាក់ស្លាក ផ្ទាំងរូបភាព ខិតប័ណ្ណឃោសនា ការរារាំង រំខានសកម្មភាពឃោសនា ករណី ចែកអំណោយក្នុងន័យទិញសន្លឹកឆ្នោត មានសរុបប្រមាណ **១៥១** ករណី។

ជាសរុប យើងសង្កេតឃើញថា បរិយាកាសមុនថ្ងៃបោះឆ្នោត ហាក់ដូចជានាំមកនូវការព្រួយបារម្ភអំពីកម្រិតនៃការ ចូលរួមរបស់អ្នកបោះឆ្នោត ដោយឡែកនៅខេត្តព្រះវិហារ។ ករណីឃាតកម្ម ការគំរាមកំហែង បំភិតបំភ័យ និងភាពមិន ប្រក្រតីសម្រាប់ការបោះឆ្នោតមានចំនួនតិចជាងការបោះឆ្នោតជាតិលើកមុនៗ តែទោះជាយ៉ាងណាក៏ករណីដែលបានកើត ឡើងនេះនៅតែធ្វើឱ្យមានការប៉ះពាល់អារម្មណ៍អ្នកបោះឆ្នោតដដែល។ មិនតែប៉ុណ្ណោះ យើងនៅមានការព្រួយបារម្ភថា បញ្ហាទាំងនេះនឹងអាចកើតឡើងទៅថ្ងៃក្រោយទៀត។ ដើម្បីអាចបញ្ចៀសឱ្យបាននូវបញ្ហាអវិជ្ជមានទាំងនេះ សម្ព័ន្ធអង្គការ សង្គមស៊ីវិល សូមចូលរួមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោមនេះ:

- *សូមស្ថាប័នមានសមត្ថកិច្ចទប់ស្កាត់ឱ្យបាននូវករណីឃាតកម្ម គំរាមកំហែង និងបំភិតបំភ័យដល់សកម្មជនគណ-បក្សនយោបាយ និងអ្នកបោះឆ្នោតនៅក្នុងថ្ងៃ ស ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។*

---

[២] យោងតាមរបាយការណ៍អង្កេតរបស់បណ្តាញ ខុមហ្វ្រែល-អាដហុក។

[៣] ដូចលេខ ២។

- *សូមស្ថាប័នមានសមត្ថកិច្ចមានវិធានការណ៍ស៊ើបអង្កេតលើករណីឃាតកម្ម ការបង្ករបួសស្នាម ការគំរាមកំហែង និងចាប់ខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់ជាធរមាន ។*

- *សូមស្ថាប័នមានសមត្ថកិច្ចទប់ស្កាត់ឱ្យបាន នូវករណីទិញសន្លឹកឆ្នោត (ទាំងឱ្យទៅបោះឆ្នោត ឬរារាំងមិនឱ្យទៅបោះឆ្នោត) ជាពិសេសនៅក្នុងថ្ងៃ ស*

- *សូមកុំឱ្យកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីរាជការ អាជ្ញាធរមូលដ្ឋានចូលរួមធ្វើសកម្មភាព គាំទ្រគណ-បក្សនយោបាយណាមួយនៅក្នុង ឬនៅក្បែរបរិវេណនៃទីតាំងការិយាល័យបោះឆ្នោត*

- *សូមឱ្យមន្ត្រីការិយាល័យបោះឆ្នោត (ជំនួយការទី ២) ត្រូវខិតខំយកចិត្តទុកដាក់ជួយអ្នកបោះឆ្នោត (គ្មានប័ណ្ណព័ត៌មាន) ដើម្បីរកការិយាល័យបោះឆ្នោត ។*

- *សូមអំពាវនាវដល់ប្រជាពលរដ្ឋអ្នកបោះឆ្នោត គួរទៅបោះឆ្នោតកុំខាន បើទោះបីជួបនូវបញ្ហាបន្តិចបន្តួច*

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទងវាគ្មិនៈ*

- លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល ប្រធានគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគមអាដហុក ទូរស័ព្ទៈ ០១៦ ៨៨០ ៥០៩
- លោក **សុក សំអឿន** អនុប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល និងជានាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ទូរស័ព្ទៈ ០១២ ៩០១ ១៩៩
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទៈ ០១២ ៩៤២ ០១៧
- លោក **ហង្ស ពុទ្ធា** នាយកប្រតិបត្តិ និកហ្វិច ទូរស័ព្ទៈ ០១២ ៩៥៩ ៦៦៦
- **Ms. Somsri Hananuntasuk, Executive Director of ANFREL, Tel. 099 378 803**
- **Mr. KUMAOKA Michiya, Co-Representative of PEFOC,J Tel. 012 787 270**